# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់៥២,៧០០ដុល្លាអាមេរិក សម្រាប់គម្រោងសាងសង់ អគារពិសោធន៍វិទ្យាសាស្ត្រ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៥២,៧០០ ដុល្លាអាមេរិកដល់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងសម្រាប់គម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ លោក គូរ៉ូមីយ៉ា តាកាយ៉ូស៊ី ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រ កម្ពុជា និងលោក ស៊ើយ វង្សស៊ុ នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងនៅស្ថានទូតជប៉ុន។

ដើម្បីផ្តល់ការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រកាន់តែប្រសើរ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងនឹងអនុវត្តគម្រោងសាងសង់អគារពិសោធន៍វិទ្យាសាស្ត្រ ដែលមានកម្ពស់មួយជាន់ ដើម្បីផ្តល់ការអប់រំផ្នែកវិទ្យាសាស្ត្រកាន់តែប្រសើរដល់គរុសិស្សប្រមាណ៣០០នាក់ ដែលនឹងក្លាយទៅជាគ្រូបង្រៀនកម្រិតបឋមសិក្សាក្នុង



ខេត្តស្ទឹងត្រែង ខេត្ត មណ្ឌលគីរី និងខេត្ត រតនគីរី ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ សង្ហារឹម និងសម្ភារៈសិក្សាដែលមានដូចជា តុពិសោធន៍ កៅអី និង ធ្នើសម្រាប់ដាក់សម្ភារៈពិសោធន៍ក៏នឹងត្រូវបានបំពាក់ផងដែរ។ យើងរំពឹងថា សិស្សានុសិស្សកម្រិតបឋមប្រមាណ៦៣,០០០នាក់នៅក្នុងខេត្តទាំងនេះ នឹងទទួលបានការអប់រំផ្នែកវិទ្យាសាស្ត្រកាន់តែប្រសើរពីលោកគ្រូ-អ្នកគ្រូ ដែលចេញពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់

ជីវភាពរស់នៅ ការ ចិញ្ចឹមជិវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯង របស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង ៤៨.៦ លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៨៥ គម្រោង នៅទូទាំង ប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*